**សលាកប័ត្រព័ត៌មាន ៖ ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់នៅកម្ពុជា**

**ទិដ្ឋភាពរួម ៖** នៅកម្ពុជាពុំមានច្បាប់ដែលអនុញ្ញាតច្បាស់លាស់ដល់អ្នកប្តូរភេទក្នុងការទទួលបាននូវការទទួលស្គាល់ផ្លូវច្បាប់ និងរដ្ឋបាលនូវអត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងឡើយ។ ប៉ុន្តែក៏ពុំមានបទប្បញ្ញត្តិច្បាប់ជាក់លាក់ណាមួយហាមប្រាមនោះដែរ។ កង្វះភាពច្បាស់លាស់ផ្នែកច្បាប់នេះនាំឲ្យមានការធ្វើសេចក្តីសម្រេចគឺអាស្រ័យលើសំណាក់មន្ត្រីពាក់ព័ន្ធទៅលើអ្នកប្តូរភេទ។ តែយ៉ាងណាក្តី មានអ្នកប្តូរភេទមួយចំនួនទទួលបានអត្តសញ្ញាណប័ណ្ណស្របទៅនឹងការកំណត់យកអត្តសញ្ញាណយេនឌ័រដោយខ្លួនឯងផងដែរ ប៉ុន្តែមន្ត្រីនៅមូលដ្ឋានភាគច្រើនបដិសេធនូវសំណើនេះដោយបារម្ភពីការរំលោភបំពានច្បាប់។ ករណីនេះចាំបាច់ត្រូវតែធ្វើការស្រាយបំភ្លឺ ដើម្បីអ្នកប្តូរភេទកម្ពុជាទាំងអស់អាចទទួលបានការទទួលស្គាល់យេនឌ័រពេលលេញតាមច្បាប់។

## ១. សេចក្តីផ្តើម

ទិវាលើកកម្ពស់ការយល់ដឹងបញ្ហាប្រឈមរបស់អ្នកប្តូរភេទអន្តរជាតិ បានប្រព្រឹត្តទៅនាថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៨។ ដើម្បីចូលរួមប្រារព្ធក្នុងទិវានេះ សលាកបត្រព័ត៌មានលើកឡើងនូវទិដ្ឋភាពទូទៅជុំវិញការទទួលស្គាល់តាមផ្លូវច្បាប់នូវការកំណត់អត្តសញ្ញាណយេនឌ័រដោយខ្លួនឯង ( ឬ " ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់")សម្រាប់អ្នកប្តូរភេទនិងអ្នកមិនបង្ហាញយេនឌ័រនៅកម្ពុជា។

សលាកប័ត្រពត៌មាននេះផលិតដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការងារដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស រួមទាំងសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និងអ្នកប្រតិព័ទ្ធភេទដូចគ្នានៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

**តើអ្នកប្តូរភេទជាអ្វី?**

ពាក្យ "អ្នកប្តូរភេទ" (ឬ"មនុស្សប្តូរភេទ") ត្រូវបានគេប្រើដើម្បីពិពណ៌នាលើបុគ្គលទាំងឡាយណាដែលអត្តយេនឌ័ររបស់គាត់មិនស៊ីសង្វាក់ជាមួយភេទដែលមានមកពីកំណើតរបស់ពួកគាត់។ ឧទាហរណ៍ អ្នកប្តូរភេទជាស្ត្រីគឺជាបុគ្គលម្នាក់ដែលបង្ហាញឱ្យឃើញតាមរយៈអារម្មណ៍ និងរបៀបនៃការរស់ដូចជាស្ត្រីប៉ុន្តែមានភេទប្រុសពីកំណើត។ អ្នកប្តូរភេទនឹងរស់នៅតាមលក្ខណៈធម្មតា និងបង្ហាញខ្លួនតាមរយៈអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ជាជាងភេទដែលពួកគេមានមកពីកំណើត ហើយអ្នកប្តូរភេទជាច្រើននឹងជ្រើសយកការប្តូរភេទជាអចិន្ត្រៃយ៍តាមរយៈនីតិវិធីវេជ្ជសាស្ត្រ ឬការវះកាត់ក្នុងដំណើរការមួយដែលគេស្គាល់ថាជាការប្តូរភេទ។

***តើ "ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់" មានន័យយ៉ាងដូចម្តេច?***

ការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមផ្លូវច្បាប់តម្រូវឱ្យមាន នីតិវិធីនានាផ្នែកច្បាប់និងរដ្ឋបាលត្រូវមានលក្ខណៈស្របគ្នាដែលអាចឱ្យការកំណត់យកយេនឌ័រដោយខ្លួនឯងរបស់អ្នកប្តូរភេទមានបញ្ជាក់នៅលើឯក

សារអត្តសញ្ញាណផ្លូវការនានារបស់ពួកគេ ដូចជា សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងប័ណ្ណបើកបរជាដើម។ គោលបំណងនៃការទទួលស្គាល់យេនឌ័រតាមច្បាប់គឺដើម្បីបញ្ចៀសគម្លាតរវាងភេទដែលមានបញ្ជាក់ក្នុងឯកសារអត្តសញ្ញាណផ្លូវការនានា (ជាទូទៅសំដៅលើភេទពីកំណើត) និងអត្តសញ្ញាណយេនឌ័រជាក់ស្តែងរបស់អ្នកប្តូរភេទតាមរយៈការធ្វើឱ្យមានសង្គតិភាពជាផ្លូវការ និងការកំណត់យកយេនឌ័រដោយខ្លួនឯង។ យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការវះកាត់ប្តូរភេទមិនត្រូវជាលក្ខខណ្ឌតម្រូវឱ្យធ្វើជាមុនដើម្បីទទួលបានការទទួលស្គាល់យេនឌ័រតាមច្បាប់ឡើយ។

អ្នកប្តូរភេទប្រឈមនឹងការរើសអើងនិងការផាត់ចេញក្នុងកម្រិតខ្ពស់ហើយជារឿយៗពួកគាត់ពុំត្រូវបានគេផ្តល់ការគោរព កិត្តិយស ឬសន្តិសុខក្នុងនាមជាអ្នកប្តូរភេទឡើយ។[1] នេះកាន់តែធ្ងន់ធ្ងរទៅទៀតនៅពេលដែលឯកសារផ្លូវការនានារបស់គាត់ពុំស្របជាមួយនឹងអត្តសញ្ញាណយេនឌ័ររបស់ខ្លួន ឬ នៅពេលដែលពួកគាត់ត្រូវឆ្លងកាត់នីតិវិធីដែលមិនទាក់ទងនឹងការប្តូរភេទ។ ការបដិសេធក្នុងការទទួលស្គាល់យេនឌ័រតាមច្បាប់អាចនាំឱ្យមានការបដិសេធសិទ្ធិមនុស្សមួយចំនួនធំផ្សេងៗទៀត ដូចជា សិទ្ធិទទួលបានសុខភាព សិទ្ធិទទួលបានការងារ និងសិទ្ធិរស់ក្នុងជីវភាពមួយសមរម្យ ដោយហេតុថាអ្នកប្តូរភេទដែលពុំមានការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ ជារឿយៗត្រូវបានគេផាត់ចេញពីការទទួលបានការងារ ការអប់រំ សេវាថែទាំសុខភាព និងសេវាផ្នែកធនាគារជាដើម។[2] ការផាត់ចេញនេះថែមទាំងប៉ះពាល់ដល់សកម្មភាពប្រចាំថ្ងៃទាក់ទងនឹងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណក្នុងសកម្មភាពសំខាន់ៗមួយចំនួនផងដែរ ដូចជា ការចូលទៅក្នុងអគារមួយចំនួន ឬការទទួលអ៊ីម៉ែលជាដើម។

នៅលើសកលលោក មានការវិវត្តកាន់តែច្រើនឡើងឆ្ពោះទៅរកការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់សម្រាប់អ្នកប្តូរភេទ ផ្អែកតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋជាច្រើនបានបង្កើតច្បាប់ទទួលស្គាល់យេនឌ័ររួមមាន អាហ្សង់ទីន កូឡុំប៊ី អៀរឡង់ ម៉ាល់តា ដាណឺម៉ាក និង ន័រវែស ហើយជាពិសេសប្រទេសវៀតណាម។ ប្រទេសវៀតណាមបានបង្កើតមាត្រា៣៧ ក្នុងក្រមរដ្ឋប្បវេណី[3]របស់ខ្លួនក្នុងខែមករា ឆ្នាំ២០១៧ ដែលអនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមផ្លូវច្បាប់នៅលើឯកសារផ្លូវការនានា។[4]ច្បាប់ទទួលស្គាល់យេនឌ័ររបស់ប្រទេសអាហ្សង់ទីននិងប្រទេសម៉ាល់តាត្រូវគេមើលឃើញថាជាប្រព័ន្ធគំរូព្រោះថាច្បាប់ទាំងនេះបញ្ជាក់ពីសិទ្ធិរបស់អ្នកប្តូរភេទក្នុងការធ្វើស្វ័យសម្រេចពីអត្តសញ្ញាណយេនឌ័រតាមច្បាប់ ដែលពុំតម្រូវឱ្យមានលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ ឬក៏ការធ្វើរោគវិនិច្ឆ័យណាមួយឡើយ។

---

[1] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ " ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ ៖ ទិដ្ឋភាពផ្នែកច្បាប់ និងគោលនយោបាយរបស់ប្រទេសជាច្រើននៅអាស៊ី" ឆ្នាំ២០១៧ ទំព័រ ២៣។

[2] ប្រភពដដែល ទំព័រ ២៧

[3] ក្រមរដ្ឋប្បវេណី និងអនុក្រឹត្យលេខ ៨៨/២០០៨ ND-CP មាត្រា ៣៧

[4] សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ឧភតោភេទ ប្តូរភេទ និងអន្តរភេទ " របាយការណ៍ផែនទីផ្លូវច្បាប់នៃអ្នកប្តូរភេទ" ខែវិច្ឆិកា ឆ្នាំ២០១៧ ទំព័រ ៤៩។

នៅកម្រិតអង្គការសហប្រជាជាតិមានការពិភាក្សាសំខាន់ៗជុំវិញការទទួលស្គាល់យេនឌ័រតាមច្បាប់។ ភ្នាក់ងារអង្គការសហប្រជាជាតិចំនួន១២ រួមមាន ការិយាល័យនៃឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ (OHCHR) ទីភ្នាក់ងារដើម្បីជនភៀសខ្លួនអង្គការសហប្រជាជាតិ (UNCHR) អង្គការដើម្បីសមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រី (UN Women) និងអង្គការសុខភាពពិភពលោក (WHO) បានចេញសេចក្តីថ្លែងការណ៍រួមមួយ ក្នុងខែកញ្ញាឆ្នាំ២០១៥ ដោយស្នើយ៉ាងជាក់លាក់ថា *"ឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមច្បាប់ដោយពុំតម្រូវលក្ខខណ្ឌបំពាននានា"*។[5] ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិដែលបានរាយការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សដោយបានបញ្ជាក់ច្បាស់ថារដ្ឋនានាត្រូវតែគោរពអត្តសញ្ញាណរបស់អ្នកប្តូរភេទដោយត្រូវទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងរបស់ពួកគេ ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ហើយនេះត្រូវតែមានបញ្ជាក់នៅលើឯកសារអត្តសញ្ញាណផ្លូវច្បាប់នានាផងដែរដោយពុំតម្រូវឱ្យមានលក្ខខណ្ឌបន្ថែមដែលអាចរំលោភសិទ្ធិមនុស្សថែមទៀត។[6]

## ២. ការទទួលស្គាល់យេនឌ័រតាមច្បាប់នៅកម្ពុជា

នៅកម្ពុជាពុំមានច្បាប់ដែលអនុញ្ញាតច្បាស់លាស់ដល់អ្នកប្តូរភេទក្នុងការទទួលបាននូវការទទួលស្គាល់ផ្លូវច្បាប់និងរដ្ឋបាលនូវអត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងឡើយ។ ប៉ុន្តែក៏ពុំមានបទប្បញ្ញត្តិច្បាប់ជាក់លាក់ណាមួយហាមប្រាមនោះដែរ។ កង្វះភាពច្បាស់លាស់ផ្នែកច្បាប់នេះនាំឲ្យមានការធ្វើសេចក្តីសម្រេចដោយឯកឯងពីសំណាក់មន្ត្រីពាក់ព័ន្ធទៅលើអ្នកប្តូរភេទ។ តែយ៉ាងណាក្តី មានអ្នកប្តូរភេទមួយចំនួនទទួលបានអត្តសញ្ញាណប័ណ្ណស្របទៅនឹងការកំណត់យកអត្តសញ្ញាណយេនឌ័រដោយខ្លួនឯងផងដែរ ប៉ុន្តែមន្ត្រីនៅមូលដ្ឋានភាគច្រើនបដិសេធនូវសំណើនេះដោយបារម្ភពីការរំលោភបំពានច្បាប់។ ករណីនេះចាំបាច់ត្រូវតែធ្វើការស្រាយបំភ្លឺ ដើម្បីអ្នកប្តូរភេទកម្ពុជាទាំងអស់អាចទទួលបានការទទួលស្គាល់យេនឌ័រពេលលេញតាមច្បាប់។

### ២.១ នីតិវិធីរដ្ឋបាល និងបច្ចេកទេសទាក់ទងនឹងអត្តសញ្ញាណប័ណ្ណនៅកម្ពុជា ៖

- *អនុក្រឹត្យស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ៣៦ អនក្រ/បក/២៦ កក្កដា ឆ្នាំ១៩៩៦*
- *ប្រកាសលេខ ៦៣៧៥ ស្តីពីនីតិវិធី លក្ខខណ្ឌនៃការសុំ ការផ្តល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចេញដោយក្រសួងមហាផ្ទៃ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥*

ការចេញអត្តសញ្ញាណប័ណ្ណគឺគ្រប់គ្រងដោយអនុក្រឹត្យលេខ ៣៦ អនក្រ/បក និងប្រកាសលេខ ៦៣៧៥។

[5] ILO; OHCHR; UNAIDS; UNDP; UNESCO; UNFPA; UNHR; UNICEF; UNODC; UN Women; WFP; WHO "ការរើសអើង និងអំពើហិង្សាទៅលើបុគ្គលផ្អែកលើនិន្នការភេទ និងអត្តសញ្ញាណយេនឌ័រ" ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ក/គ.ស.ម/២៩/២៣ ។

[6] របាយការណ៍របស់ការិយាល័យនៃឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ " ការរើសអើង និងអំពើហិង្សាទៅលើបុគ្គលផ្អែកលើនិន្នការភេទនិងអត្តសញ្ញាណយេនឌ័រ" (ក/គ.ស.ម/២៩/២៣) ឆ្នាំ២០១៥ កថាខ័ណ្ឌ៧៩ (ឈ)។

អ្នកស្នើសុំត្រូវទៅកាន់ប៉ុស្តិ៍នគរបាលដែលស្ថិតនៅក្នុងឃុំ/សង្កាត់ ឬ ស្រុករបស់ខ្លួនដោយផ្ទាល់ ដោយយកទៅជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម ៖

- សំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចាស់ ឬ
- សាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា ជននោះកើតពីឳពុក ឬម្តាយ ដែលមានសញ្ជាតិខ្មែរ ឬ
- ឯកសារ ឬភស្តុតាងជាផ្លូវការ ដែលបញ្ជាក់ថា សាមីជនកើតមកពីឳពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

ប្រកាសឆ្នាំចេញ២០១៥ បានកំណត់ថាអ្នកស្នើសុំត្រូវបំពេញទម្រង់បែបបទនិងបង់ថ្លៃសេវាដែលបច្ចុប្បន្នកំណត់ថ្លៃចំនួន ១០.០០០រៀល។ ប៉ុន្តែ ការយកថ្លៃសម្រាប់អត្តសញ្ញាប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងនីតិវិធីរដ្ឋបាលមួយចំនួនទៀតត្រូវបានលុបចេញពីលក្ខខណ្ឌតម្រូវរបស់ប្រកាសលេខ ១៤៤១៤ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។[7]

ប្រកាសឆ្នាំ២០១៥ លើកឡើងថាសំបុត្រកំណើតអាចត្រូវផ្តល់ជាភស្តុតាងបញ្ជាក់អត្តសញ្ញាណនៅពេលស្នើសុំអត្តសញ្ញាណប័ណ្ណ ប៉ុន្តែ មិនបានចែងថាព័ត៌មានផ្ទាល់ខ្លួន ដូចជា ភេទ/យេនឌ័រ ក្នុងអត្តសញ្ញាណប័ណ្ណត្រូវតែត្រូវគ្នាទាំងស្រុងជាមួយព័ត៌មានក្នុងសំបុត្រកំណើតឡើយ។ ម្យ៉ាងវិញទៀតអនុក្រឹត្យឆ្នាំ១៩៩៥ មាត្រា ៤ លើកឡើងនូវលក្ខន្តិកៈប្រាំបីយ៉ាងដែលត្រូវ "*ពិចារណា*" ដោយ "*អាជ្ញាធរមានសមត្ថកិច្ច*"។ លក្ខន្តិកៈភាគច្រើនពាក់ព័ន្ធនឹងភស្តុតាងបញ្ជាក់អត្តសញ្ញាណ ជាមួយគ្នានេះ "*សំបុត្រកំណើត*" ក៏ត្រូវបានរាប់បញ្ចូលផងដែរ។ ម្យ៉ាងទៀត មាត្រា ៨ នៃ អនុក្រឹត្យនេះបញ្ចូលនូវការពិន័យទោសចំពោះមន្ត្រីទាំងឡាយណាដែលចេញអត្តសញ្ញាណប័ណ្ណពុំត្រឹមត្រូវជូនបុគ្គលដែលពុំមែនជាជនជាតិខ្មែរ ប៉ុន្តែពុំបានបញ្ជាក់ពីការពិន័យទោសណាមួយទាក់ទងនឹងការកត់ត្រាយេនឌ័រពុំត្រឹមត្រូវលើអត្តសញ្ញាណប័ណ្ណឡើយ។

គួរកត់សម្គាល់ថាកម្ពុជាមានកាតព្វកិច្ចជាវិជ្ជមានក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិដើម្បីធានាថាច្បាប់ក្នុងស្រុកមានប្រសិទ្ធិភាពក្នុងការការពារសិទ្ធិដែលមាននៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាបានផ្តល់សច្ចាប័ន[8]។ ទោះជាយ៉ាងណាក៏ដោយសំរាប់បញ្ហាក្នុងការផ្លាស់ប្តូរភេទឬយេនឌ័រនៅលើអត្តសញ្ញាណប័ណ្ណបច្ចុប្បន្នមិនត្រូវបានដោះស្រាយដោយបទបញ្ជាផ្ទៃក្នុងដែលពាក់ព័ន្ធនោះគម្លាតនៅក្នុងច្បាប់គួរតែត្រូវបានបកស្រាយស្របតាមបទដ្ឋានសិទ្ធិមនុស្សតាមរដ្ឋធម្មនុញ្ញនិងអន្តរជាតិដូចដែលបានគូសបញ្ជាក់ខាងក្រោមនេះ។

[7] ប្រកាសអន្តរក្រសួងលេខ ១៤៤១៤ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។

[8] ប្រកាសអន្តរក្រសួងលេខ ១៤៤១៤ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។

## ៣. ច្បាប់សិទ្ធិមនុស្សដែលត្រូវអនុវត្ត

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") បានចែងពីការគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា។[9] ការអនុវត្តដោយផ្ទាល់នូវបញ្ញត្តិច្បាប់អន្តរជាតិទាំងនេះត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់តាមរយៈសេចក្តីសម្រេចមួយចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។[10] នេះរាប់បញ្ចូលទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម")[11] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")[12] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ផងដែរ។[13] ប្រទេសកម្ពុជាជាប់កាតព្វកិច្ចអនុវត្តដោយសុទ្ធចិត្តនូវអនុសញ្ញាអន្តរជាតិទាំងនោះដែលកម្ពុជាគឺជាភាគីមួយ ហើយកម្ពុជាមិនអាចផ្អែកទៅលើបទប្បញ្ញត្តិនានានៃច្បាប់ជាតិក្នុងការផ្តល់ហេតុផលចំពោះការខកខានក្នុងការបំពេញកាតព្វកិច្ចតាមអនុសញ្ញាទាំងនេះឡើយ។[14]

### ៣.១ សិទ្ធិទទួលបានការទទួលស្គាល់យេនឌ័រតាមច្បាប់

សិទ្ធិទទួលស្គាល់យេនឌ័រតាមច្បាប់មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថាជាសិទ្ធិមួយដាច់ដោយឡែកនៅក្នុងអនុសញ្ញាអន្តរជាតិណាមួយឡើយ។ ប៉ុន្តែ នេះជាការតម្រូវឱ្យមានការទទួលស្គាល់សិទ្ធិនេះដើម្បីបំពេញសិទ្ធិមនុស្សដែលត្រូវការពារយ៉ាងជាក់លាក់ដទៃទៀត ក្នុងនោះមានដូចជា សិទ្ធិរួចផុតពីការរើសអើង សិទ្ធិក្នុងការធ្វើស្វ័យសម្រេច សិទ្ធិទទួលបានការទទួលស្គាល់ជាមនុស្សចំពោះមុខច្បាប់(សិទ្ធិនីមួយៗមានគូសបញ្ជាក់ខាងក្រោម)។

គោលការណ៍ ៣១ នៃគោលការណ៍យ៉កយ៉ាកាតា ស្តីពីគោលការណ៍អន្តរជាតិ និងកាតព្វកិច្ចរដ្ឋនានាស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ លើកឡើងពីវិសាលភាពនៃសិទ្ធិទទួលបានការទទួលស្គាល់យេនឌ័រតាមច្បាប់ផ្អែកតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ គោលការណ៍នេះចែងថា ៖

---

[9] សូមមើលអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ៣១ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៤ កថាខ័ណ្ឌ៨, ១៣ អាចរកបានតាមរយៈ https://bit.ly/1OI6PbI
រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[10] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧

[11] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នៃមហាសន្និបាតអង្គការសហប្រជាជាតិ អនុម័តថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨

[12] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៃមហាសន្និបាតអង្គការសហប្រជាជាតិ អនុម័ត ឆ្នាំ១៩៦៦ និងត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជាឆ្នាំ ១៩៩២។

[13] "កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានអនុម័តនៅឆ្នាំ "១៩៦៦ ។ បានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ ។

[14] អនុសញ្ញាវីយែន មាត្រា ២៧

*«មនុស្សគ្រប់រូបមានសិទ្ធិទទួលបានឯកសារអត្តសញ្ញាណនានា ក្នុងនោះរួមមានទាំង សំបុត្រកំណើត ដោយពុំគិតពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ ឬលក្ខណៈភេទនានា។ មនុស្សគ្រប់រូបមានសិទ្ធិប្តូរព័ត៌មានយេនឌ័រក្នុងឯកសារទាំងនេះនៅពេលដែលព័ត៌មានទាំងនេះត្រូវបានបញ្ចូល»*។[15]

គោលការណ៍នេះក៏គូសបញ្ជាក់ដែរថា យន្តការដើម្បីទទួលស្គាល់តាមច្បាប់នូវការកំណត់យកយេនឌ័រដោយខ្លួនឯងរបស់បុគ្គលណាម្នាក់ត្រូវតែ *«រហ័ស តម្លាភាព និងអាចយល់បាន»* ហើយមិនត្រូវផ្អែកលើលក្ខខណ្ឌតម្រូវផ្នែក *«វេជ្ជសាស្ត្រ ចិត្តសាស្ត្រ ឬធ្វើពោគវិនិច្ឆ័យ អាយុអប្បបរមា ឬអតិបរមា ស្ថានភាពសេដ្ឋកិច្ច សុខភាព ស្ថានភាពគ្រួសារ ឬមាតាបិតា ឬក៏គំនិតរបស់តតិយជនដទៃទៀតឡើយ»*។

តាមរយៈរបាយការណ៍មួយចេញផ្សាយក្នុងឆ្នាំ២០១៧ អ្នកជំនាញឯករាជ្យលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ច្បាស់ថាការមិនអាចឱ្យមានការទទួលស្គាល់យេនឌ័រតាមការកំណត់យកយេនឌ័រដោយខ្លួនឯងរបស់នរណាម្នាក់ពីសំណាក់រដ្ឋ *«នាំទៅរកអំពើហិង្សានិងការរើសអើង»*។[16] លោកបានផ្តល់អនុសាសន៍ថារដ្ឋនានាចាំបាច់ត្រូវតែ *«ធ្វើដំណើរឆ្ពោះទៅរកការទទួលស្គាល់តាមច្បាប់នូវការកំណត់យកយេនឌ័រដោយខ្លួនឯងដោយពុំមានការបង្ខិតបង្ខំ»* ដែលបានលើកយកប្រទេសអាហ្សង់ទីន និងប្រទេសម៉ាល់តាជាគំរូ។[17]

ស្ថាប័នអនុសញ្ញាអង្គការសហប្រជាជាតិបានសម្តែងកង្វល់អំពីការទទួលស្គាល់យេនឌ័រតាមច្បាប់តាមរយៈអនុសាសន៍របស់ពួកគេដែលផ្តល់ទៅកាន់រដ្ឋជាក់លាក់មួយចំនួន។ នាពេលថ្មីៗនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់អនុសាសន៍មួយចំនួនដល់សាធារណរដ្ឋស្លូវ៉ាគី ប្រទេសស៊ែប៊ី និងកូរ៉េខាងត្បូងអំពីការអនុវត្តនីតិវិធីទទួលស្គាល់យេនឌ័រតាមច្បាប់។[18] គណៈកម្មាធិការដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) បានស្នើឱ្យមាននីតិវិធីទទួលស្គាលយេនឌ័រតាមច្បាប់ប្រកបដោយ " ប្រសិទ្ធភាព តម្លាភាព ឬ ងាយយល់ " ហើយស្ថាប័នអនុសញ្ញាមួយចំនួន រួមមាន គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មនិងគណៈកម្មាធិការដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ បានផ្តល់អនុសាសន៍ឱ្យលុបចេញនូវលក្ខខណ្ឌតម្រូវឱ្យមានការវាយតម្លៃលើ "សតិអារម្មណ៍ ការក្រៀវមេជីវិត ឬការវះកាត់"[19] ជាលក្ខខណ្ឌតម្រូវមួយមុនទទួលបានការទទួលស្គាល់តាមច្បាប់នូវការកំណត់យកយេនឌ័រដោយខ្លួនឯង។

---

[15] គោលការណ៍យ៉កយ៉ាកាតា ឧបសម្ព័ន្ធ ១០ អនុម័តថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧

[16] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិៈ "របាយការណ៍របស់អ្នកជំនាញឯករាជ្យស្តីពីកិច្ចការពារជំទាស់នឹងអំពើហិង្សា និងការរើសអើងដោយផ្អែកលើនិន្នការភេទនិងអត្តសញ្ញាណយេនឌ័រ" (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧) ក/គ.ស.ម/៣៥ កថាខ័ណ្ឌ៥៧

[17] ប្រភពខាងលើ

[18] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិៈ "ការធ្វើសេចក្តីសន្និដ្ឋានលើរបាយការណ៍នៃការត្រួតពិនិត្យជាសកលលើកទីបីលើប្រទេសស៊ែប៊ី ) ក.អ.ស.ព.ន CCPR/C/SRB/CO/3 ការធ្វើសេចក្តីសន្និដ្ឋានលើរបាយការណ៍នៃការត្រួតពិនិត្យតាមកាលកំណត់លើកទីបួនលើសាធារណៈរដ្ឋកូរ៉េ CCPR/C/KOR/CO/4.

[19] CEDAW/C/BEL/CO/7

## ៣.២ សិទ្ធិទទួលបានសមភាព និងការមិនរើសអើង

*រដ្ឋធម្មនុញ្ញកម្ពុជា*

តាមឋានានុក្រមនៃច្បាប់ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃប្រទេសកម្ពុជា មិនបានបញ្ជាក់ដោយផ្ទាល់អំពីអ្នកស្រឡាញ់ភេទដូចគ្នា។ តែយ៉ាងណាក្តី មាត្រា ៣១ ធានាសិទ្ធិស្មើភាពចំពោះប្រជាពលរដ្ឋគ្រប់រូបដោយពុំគិតពីបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនឡើយ ដែលចែងថា ៖

*«ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ...ឬ ស្ថានភាពឯទៀតឡើយ»*។

*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*

មាត្រា ២ ៖ « *១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជ សាសន៍ ពណ៌សម្បុរ ភេទ ភាសា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ*»។

មាត្រា ៣៖ « *រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ*»។

មាត្រា ២៦ ៖«*ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារពីច្បាប់ស្មើគ្នាដោយឥតរើសអើង ក្នុងប្រការនេះច្បាប់ត្រូវហាមការរើសអើង និងត្រូវធានាឱ្យជនគ្រប់រូបនូវការការពារសិទ្ធិស្មើគ្នាប្រឆាំងការរើសអើងទាំងឡាយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ កំណើតឬស្ថានភាពដទៃទៀត*» ។

*សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស*

មាត្រា ១៖ «*មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរៈភាពជាបងប្អូន*»។

មាត្រា ២៖ « *មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតៗឡើយ*»។

មាត្រា ៧៖ «*មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗភាពគ្នាដោយគ្មានការរើសអើង។ មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង*»។

## ៣.៣ សិទ្ធិស្វ័យសម្រេច សិទ្ធិអភិវឌ្ឍបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន និងសិទ្ធិទទួលបានការទទួលស្គាល់ជាមនុស្សចំពោះមុខច្បាប់

មាត្រា១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ("ក.អ.ស.ស.វ") ចែងថាប្រជាជាតិទាំងអស់មានសិទ្ធិស្វ័យសម្រេច កំណត់ដោយសេរីនូវឋានៈនយោបាយ និងខិតខំអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី។[20] ការបដិសេធក្នុងការទទួលស្គាល់តាមច្បាប់នូវអត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងនៅលើឯកសារផ្លូវការ ធ្វើឱ្យប៉ះពាល់ដល់ស្វ័យភាពរបស់បុគ្គលនិងរារាំងនូវការអនុវត្តជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ។ ម្យ៉ាងទៀតមាត្រា ២៩ នៃ ស.ស.ស.ម បានគូសបញ្ជាក់ថាមនុស្សគ្រប់រូបមានសិទ្ធិ *«ធ្វើការអភិវឌ្ឍដោយសេរី និងពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន»*។ ដូចមានបញ្ជាក់ក្នុងគោលការណ៍ ៣ នៃគោលការណ៍យ៉កយ៉ាកាតាដែលជាបណ្តុំនៃគោលការណ៍អន្តរជាតិទាក់ទងនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ហើយនិងសិទ្ធិមនុស្ស ដែលនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងរបស់បុគ្គលម្នាក់ៗ គឺជា *«ផ្នែកសំខាន់សម្រាប់បុគ្គលិកលក្ខណៈរបស់ពួកគេ ហើយនេះជាទិដ្ឋភាពដ៏សំខាន់មួយក្នុងចំណោមទិដ្ឋភាពនានានៃការធ្វើស្វ័យសម្រេច សេចក្តីថ្លៃថ្នូរ និងសេរីភាព»*។[21]

មាត្រា១៦ នៃ ក.អ.ស.ព.ន ចែងថា បុគ្គលគ្រប់រូបមាន *«សិទ្ធិឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តនៅគ្រប់ទីកន្លែង»*។ សិទ្ធិនេះក៏មានគូសបញ្ជាក់ក្នុងមាត្រា ៦ នៃ ស.ស.ស.ម និងគោលការណ៍ ៣ នៃគោលការណ៍យ៉កយ៉ាកាតាផងដែរ។ កាលដែលអ្នកប្តូរភេទមិនត្រូវគេទទួលស្គាល់ពិតប្រាកដទៅតាមអត្តសញ្ញាណដើមរបស់ពួកគេក្នុងឯកសារផ្លូវការនានាជាការបដិសេធដោយពេញលេញនូវការទទួលបានសិទ្ធិនេះ។

## ៣.៤ សិទ្ធិទទួលបានបូរណភាពខាងរូបរាងកាយ និងផ្លូវចិត្ត

គោលការណ៍ ៣២ នៃគោលការណ៍យ៉កយ៉ាកាតាបានគូសបញ្ជាក់អំពីសិទ្ធិទទួលបានបូរណភាពខាងរូបរាងកាយនិងផ្លូវចិត្តរបស់ខ្លួនដោយចែងថា *«មនុស្សគ្រប់រូបមានសិទ្ធិទទួលនូវបូរណភាពខាងផ្លូវកាយនិងផ្លូវចិត្ត ស្វ័យភាព និងការធ្វើស្វ័យសម្រេច ដោយមិនគិតពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ ឬ បុគ្គលិកលក្ខណៈផ្នែកផ្លូវភេទឡើយ»*។

តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR) បានរកឃើញក្នុងករណី ហ្គាខុន និងនីកុត (Garcon and Nicot) ដែលប្តឹងជំទាស់នឹងប្រទេសបារាំងកាលពីខែមេសាឆ្នាំ២០១៧ ដែលតម្រូវឱ្យមានការក្រៀវ ឬ នីតិវិធីវេជ្ជសាស្ត្រដទៃទៀតដែលជាលក្ខខណ្ឌតម្រូវមុនដំបូងមួយដើម្បីទទួលបានការទទួលស្គាល់យេនឌ័រតាមច្បាប់ថាជាការរំលោភបំពានលើសិទ្ធិទទួលបានបូរណភាពខាងផ្លូវកាយរបស់បុគ្គល។

[20] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃមហាសន្និបាតអង្គការសហប្រជាជាតិ អនុម័ត ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦

[21] គោលការណ៍យ៉កយ៉ាកាតា

ស្រដៀងគ្នានេះដែរ គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មអង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍ដល់ហុងកុងឱ្យ *«ដកចេញលក្ខខណ្ឌតម្រូវដែលមានលក្ខណៈរំលោភបំពាន ដើម្បីការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមច្បាប់»* ដូចជាការក្រៀវ ឬលក្ខខណ្ឌតម្រូវផ្នែកវេជ្ជសាស្ត្រផ្សេងទៀត *«ដើម្បីធានាឱ្យមានការគោរពដល់សិទ្ធិស្វ័យភាពនិងបូរណភាពខាងផ្លូវកាយនិងផ្លូវចិត្តរបស់អ្នកប្តូរភេទ»*។[22]

## ៤. សេចក្តីសម្រេចរបស់តុលាការអន្តរជាតិដែលពាក់ព័ន្ធ

<u>*ប្រទេសនេប៉ាល់*</u>: ក្នុងឆ្នាំ២០០៧ ជាសេចក្តីសម្រេចលើកដំបូងមួយនៅតំបន់អាស៊ី តុលាការកំពូលនៅក្នុងរដ្ឋយ៉ាដាវផេន នៃប្រទេសនេប៉ាល់បានចេញសេចក្តីសម្រេចបើកផ្លូវឱ្យអ្នកប្តូរភេទអាចប្តូរឈ្មោះរួមទាំងអត្តសញ្ញាណយេនឌ័រដោយផ្អែកលើលក្ខណៈវិនិច្ឆ័យផ្នែក "អារម្មណ៍ផ្ទាល់ខ្លួន" របស់បុគ្គលនោះតែម្យ៉ាងដោយយោងតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។[23]

<u>*ប្រទេសឥណ្ឌា*</u>: ក្នុងឆ្នាំ២០១៤ តុលាការកំពូលបានលើកតម្កើងសិទ្ធិអ្នកប្តូរភេទទោះបីជាបុគ្គលនោះបង្ហាញអត្តសញ្ញាណជាបុរសភេទ ស្ត្រីភេទ ឬក៏ភេទទីបីក្តី ក្នុងករណីដ៏ល្បីរន្ទឺមួយរវាងអាជ្ញាធរសេវាផ្នែកច្បាប់ជាតិឥណ្ឌា (NALSA) ជាមួយសហភាពឥណ្ឌា ( Union of India) ។[24] យោងតាមគោលការណ៍យ៉កយ៉ាកាតាការវិនិច្ឆ័យរបស់អាជ្ញាធរសេវាផ្នែកច្បាប់ជាតិឥណ្ឌា លើកឡើងថា ការបង្ហាញអត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងរបស់បុគ្គលគឺជាគោលការណ៍ដែលមានឥទ្ធិពលគ្រប់ដណ្តប់លើការទទួលស្គាល់យេនឌ័រតាមច្បាប់ ជាជាងការតម្រូវលក្ខខណ្ឌណាមួយដទៃទៀត ដូចជាការវះកាត់ ឬការតម្រូវផ្នែកវេជ្ជសាស្ត្រជាដើម។ បច្ចុប្បន្ននេះអាចធ្វើទៅបាននៅឥណ្ឌាក្នុងការប្តូរយេនឌ័រទៅកាន់យេនឌ័រតាមការកំណត់យករបស់ខ្លួន ដោយពុំតម្រូវលក្ខខណ្ឌបន្ថែមលើទម្រង់បែបបទសម្រាប់ធ្វើអត្តសញ្ញាណប័ណ្ណឡើយ ក្នុងនោះមានដូចជា ប័ណ្ណទម្រង់អេឡិចត្រូនិចអេដាន Aadar cards (ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណតែមួយនៅប្រទេសឥណ្ឌា) អត្តសញ្ញាណប័ណ្ណសម្រាប់អ្នកបោះឆ្នោតនិងអត្តសញ្ញាណប័ណ្ណពន្ធដារ ទោះជាយ៉ាងណាមិនអនុវត្តលើលិខិតឆ្លងដែនឡើយ។

<u>*តុលាការសិទ្ធិមនុស្សអឺរ៉ុប*</u>: ក្នុងខែមេសា ឆ្នាំ ២០១៧ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថាការតម្រូវឱ្យមាននីតិវិធីវេជ្ជសាស្ត្រឬការក្រៀវមេជីវិតដែលជាលក្ខខណ្ឌមុនដំបូងដើម្បីទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រនោះគឺ ជាការរំលោភសិទ្ធិទទួលបានការគោរពបូរណភាពខាងរូបរាងកាយ និងផ្លូវចិត្ត

---

[22] CAT/C/CHN-HKG/CO/5

[23] ករណីសកម្មជនស្រឡាញ់ភេទដូចគ្នា ស៊ូនីល បាប៊ូ ផែន និងករណីផ្សេងទៀត ហើយនិងករណីរដ្ឋាភិបាលនេប៉ាល់ និងករណីផ្សេងទៀត (ឆ្នាំ២០១៧) សំណុំរឿងលេខ ៩១៧ សាលដីកាសម្រេចលេខ ២០៦៤BS របស់តុលាការកំពូលនៃប្រទេសនេប៉ាល់ (ឆ្នាំ២០០៧)។ សូមមើលអត្ថបទចេញផ្សាយរបស់អង្គការយូអិនឌីភីអំពីការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ ៖ "ទិដ្ឋភាពច្បាប់និងគោលនយោបាយក្នុងបណ្តាប្រទេសនៅតំបន់អាស៊ី" ឆ្នាំ២០១៧ ទំព័រ ៣៣។

[24] អាជ្ញាធរជាតិបម្រើសេវាច្បាប់ នៃសហភាពឥណ្ឌា (ឆ្នាំ២០១៤) សាលដីកាតុលាការកំពូលលេខ៤៣៨។ សូមមើលផងដែរនូវអត្ថបទចេញផ្សាយរបស់អង្គការយូអិនឌីភីទំព័រ៣៣។

របស់បុគ្គល។[25] ការអនុវត្តតាមសេចក្តីសម្រេចនេះរបស់តុលាការជាច្រើន ជាការបង្កើតនូវកាតព្វកិច្ចវិជ្ជមានទៅលើរដ្ឋជា សមាជិកមួយចំនួនដើម្បីផ្តល់ការទទួលស្គាល់យេនឌ័រតាមច្បាប់។[26]

## ៦. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

ពុំមានច្បាប់ហាមប្រាមអាជ្ញាធរក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណស្របតាមអត្តសញ្ញាណយេនឌ័រតាមការកំណត់យកដោយខ្លួនឯងឡើយ។ ប៉ុន្តែការពុំមានច្បាប់ ប្រាកដជាអាចធ្វើឱ្យអ្នកប្តូរភេទនៅកម្ពុជាជាច្រើនពុំទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់ដែលជាសិទ្ធិមូលដ្ឋានរបស់ខ្លួនឡើយ។ ហេតុដូច្នេះ ក្នុងករណីពុំមានច្បាប់ទទួលស្គាល់យេនឌ័របែបនេះ អាជ្ញាធរមូលដ្ឋាន គួរអនុវត្តតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ហើយចេញអត្តសញ្ញាណប័ណ្ណឱ្យបានស្របតាមអត្តសញ្ញាណយេនឌ័រតាមការកំណត់អត្តសញ្ញាណខ្លួនឯងនៅពេលទទួលបានសំណើទាំងនោះ។ ម្យ៉ាងទៀត រដ្ឋាភិបាលត្រូវចាត់វិធានការដើម្បីបង្កើតច្បាប់មួយដែលទទួលស្គាល់យេនឌ័រដោយកុំបង្អង់ពេល។

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖

១.១ បង្កើតច្បាប់ទទួលស្គាល់យេនឌ័រ ដែលធានាថា៖

១.១.១ មនុស្សគ្រប់រូបដែលមានអាយុគ្រប់ ១៥ ឆ្នាំ (ដែលបង្ហាញពីនីតិភាពនៃការរួមសង្វាស យោងតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ) មានសិទ្ធិទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដែលពួកគេកំណត់ដោយខ្លួនឯងនៅលើរាល់ឯកសារផ្លូវច្បាប់ទាំងអស់ដែលចេញដោយរដ្ឋ ដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ លិខិតឆ្លងដែន ។ល។

១.១.២ កុមារដែលមានអាយុក្រោម ១៥ ឆ្នាំ មានសិទ្ធិទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដែលពួកគេកំណត់ដោយខ្លួនឯង នៅលើរាល់ឯកសារផ្លូវច្បាប់ទាំងអស់ ដែលចេញដោយរដ្ឋ នៅពេលមានការឯកភាពពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។

១.១.៣ អ្នកប្តូរភេទទាំងអស់ ដែលស្វែងរកការទទួលស្គាល់តាមផ្លូវច្បាប់លើអត្តសញ្ញាណយេនឌ័ររបស់ពួកគេ អាចធ្វើបែបនេះបាន ដោយគ្រាន់តែដាក់ពាក្យសុំតាមរយៈបែបបទរដ្ឋបាលតែប៉ុណ្ណោះ (ដំណើរការនេះអាចជាដំណើរការដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ)។

១.១.៤ ពុំមានអ្នកប្តូរភេទណាមួយនឹងត្រូវបានគេដាក់ឱ្យឆ្លងកាត់ដំណើរការវេជ្ជសាស្ត្រ ឬការធ្វើរោគវិនិច្ឆ័យ សម្រាប់ជាបុរេលក្ខខណ្ឌ ដើម្បីឱ្យមានការទទួលស្គាល់យេនឌ័ររបស់ពួកគេតាមផ្លូវច្បាប់ឡើយ។

---

[25] សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប(លេខ ៧៩៨៨៥/១២)ក្នុងករណី ហ្គាខុន និងនីកុត ជាមួយប្រទេសប្រទេសបារាំង ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧។

[26] ករណីគ្រីស្ទីន ហ្គូដវិន ជាមួយចក្រភពអង់គ្លេស (ទី១១ កក្កដា ២០០២) ករណីប្រ៊ែនជាមួយចក្រភពអង់គ្លេស (ទី២៣ ឧសភា ២០០៦) ការទទួលស្គាល់យេនឌ័ររបស់អ្នកប្តូរភេទតាមផ្លូវច្បាប់នៅអឺរ៉ុប។

១.១.៥ ពុំមានអ្នកប្លូរភេទណានឹងត្រូវបង្ខំឱ្យទទួលបានការព្យាបាលវេជ្ជសាស្ត្រ ឬការវះកាត់សម្រាប់ផ្តល់យេនឌ័រថ្មី ជាបុរេលក្ខខណ្ឌសម្រាប់ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ឡើយ។

១.១.៦ ការទទួលស្គាល់យេនឌ័រ ត្រូវពង្រីកដល់គ្រប់ផ្នែកដទៃទៀតនៃច្បាប់ ដូចជា សិទ្ធិរបស់អ្នកប្លូរភេទក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬប្រពន្ធរបស់ពួកគេជាដើម។

## អនុសាសន៍សម្រាប់ក្រុមប្រឹក្សាឃុំសង្កាត់ និងអាជ្ញាធរមូលដ្ឋានដទៃទៀត៖

២.១ ជានាចេញអត្តសញ្ញាណប័ណ្ណជូនដល់អ្នកប្លូរភេទទាំងអស់ដែលបានដាក់ពាក្យស្នើសុំ ដោយមានការបញ្ជាក់នៅលើអត្តសញ្ញាប័ណ្ណទៅតាមការកំណត់យេនឌ័រដោយខ្លួនឯងរបស់ពួកគេ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ នៃ ម.ស.ម.ក តាមរយៈទូរសព្ទលេខ៖ + ៨៥៥ ៩៧ ៩៦៦៦ ៥៦៦ ឬ អ៊ីម៉ែល៖**

[sidara.nuon@cchrcambodia.org](mailto:sidara.nuon@cchrcambodia.org)៕